## ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

### ព័ត៌មានស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន
### ជំនួយរបស់ជប៉ុនសំរាប់គំរោងពង្រឹងដំណើរការកាត់ក្តី
### នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩

ជាការឆ្លើយតបចំពោះសំណើររបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុនបានធ្វើសេចក្តីសំរេចមួយក្នុងការផ្តល់វិភាគទានចំនួន **៤,១៧០,៨១៤ (បួនលានមួយសែនប្រាំពីរម៉ឺនប្រាំបីរយដប់បួន) ដុល្លារអាមេរិក** នៃមូលនិធិបដិភាគជំនួយឥតសំណងក្រៅគំរោងរបស់ជប៉ុន NPGA 2007 (Japan XI) ដើម្បីជួយបំពេញចំណែកថវិកានៃភាគីកម្ពុជាសំរាប់ការកាត់ក្តី ដែលជាផ្នែកមួយ នៃ "គំរោងពង្រឹងដំណើរការកាត់ក្តី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "។ វិភាគទាននេះនឹងជួយបំពេញកង្វះខាតថវិកា នៃភាគីកម្ពុជាសំរាប់ចំណាយលើប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ប្រទេសជប៉ុនផ្តោតសារៈសំខាន់ជាពិសេសទៅលើដំណើរវិវឌ្ឍន៍ នៃសាលាក្តីខ្មែរក្រហម ពីព្រោះខ្លួនមានជំនឿថា ដំណើរការនេះនឹងជម្រុញការលើកស្ទួយសន្តិភាព លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិបាលកិច្ចល្អនៅកម្ពុជា ។ ហេតុដូច្នេះ ទើបប្រទេសជប៉ុនបាន និងកំពុងខិតខំប្រឹងប្រែងផ្នែកការទូតយ៉ាងសកម្ម ដើម្បីសំរេចបាន និងគាំទ្រដល់សាលាក្តីខ្មែរក្រហម ដោយសហការជាមួយបណ្តាប្រទេសផ្តល់ជំនួយដទៃទៀត ។

ស្ថានទូតជប៉ុន អាស័យដ្ឋានលេខ ១៩៤ មហាវិថីព្រះនរោត្តម ទូរស័ព្ទ: ០២៣- ២១៧ ១៦១/៤ ទូរសារ: ០២៣-២១៦ ១៦២
វេបសាយផ្លូវការ : www.kh.emb-japan.go.jp